ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២១១០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី

## ការបន្តសុពលភាព សញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយ ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជា-រី)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ ចុះ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០១ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- ប្រកាសលេខ ២៤៣សហវ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០២ ស្តីពីការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជា-រី)
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១-**

បន្តសុពលភាពសញ្ញាប័ណ្ណរដ្ឋដែលបានបោះផ្សាយតាមប្រកាសលេខ ២៤៣ សហវ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០២ ស្តីពីការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជា-រី) ។

**ប្រការ ២-**

សញ្ញាប័ណ្ណរដ្ឋនេះត្រូវបានបន្តសុពលភាពចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ដល់កាលប្រតិទាននៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ ចំនួន ២.១៦០ ប័ណ្ណ (ពីរពាន់មួយរយហុកសិបប័ណ្ណ) ដែលគិតជាទឹកប្រាក់មានចំនួន ២១.៦០០.០០០.០០០ ៛ (ម្ភៃមួយពាន់ប្រាំមួយរយលានរៀល)។ ដោយមានតំលៃចារឹកក្នុងមួយឯកតា ១០.០០០.០០០ ៛ (ដប់លានរៀល) ។

**ប្រការ ៣-**

ក្នុងរយៈពេលបីឆ្នាំនេះអ្នកកាន់សញ្ញាប័ណ្ណនឹងត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% ហើយការទូទាត់ការប្រាក់នឹងត្រូវធ្វើឡើងជារៀងរាល់ ០៦ ខែ (ប្រាំមួយខែ) ម្តង ដោយឈរលើមូលដ្ឋាន ០៦ខែ ស្មើ ១៨០ ថ្ងៃ និង មួយឆ្នាំស្មើ ៣៦០ ថ្ងៃ ។

**ប្រការ ៤-**

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាប័ណ្ណរដ្ឋព្រមទាំងសហការផ្តល់ពត៌មានគ្នាទៅវិញទៅមកជាមួយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ។

**ប្រការ ៥-**

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៥ តទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា (កម្ពុជា-រី)
- ឯកសារ-កាលប្បវត្តិ